ខ្មែរប៉ុស្តិ៍ ឆ្នេរខាងកើត

Bye Bye 2009

THE KHMER POST

ISSUE 50 24th December 2009 - 09th January 2010


# សមាគមខ្មែរមានអាយុ៣០ឆ្នាំ



លោក រឿម ឡុង បង្ហាញពីសមាជិកភាពសមាគមខ្មែរ

•••សមាគមខ្មែរ បានប្រារព្ធខួបទី ៣០ឆ្នាំ របស់ខ្លួន នៅមន្ទីរសិល្បៈខ្មែរ កាលពីចុងសប្តាហ៍មុន ប្រកបដោយមោទនភាពពិសេស ។ បូណា និង មុប វ៉ាញស្តាញ ម្ចាស់អាគារមន្ទីរសិល្បៈ ប្រកបដោយវត្ថុសិល្បៈខ្មែរ ជាច្រើន សន្ធឹកសន្ធាប់គ្រប់កាលសម័យ បានបើកទទួលភ្ញៀវរបស់សមាគមខ្មែរ ហើយចូលរួមក្នុងសកម្មភាពលើកកំពស់ ប្បធម៌ខ្មែរ ដែលជំនឿនេះបានចុះថយយ៉ាងច្រើន ចាប់តាំងពីរបបកុម្មុយនីស្ត ចូលមកកាន់កាប់វ៉ាសនាកម្ពុជា ពេលណាមក ។ សមាគមខ្មែរ តាមរយៈការដឹកនាំបន្ត បន្ទាប់តាំងពី ៣០ឆ្នាំមក បានយកវប្បធម៌រុងរឿងរបស់ខ្មែរ ជាមុខព្រួញដ៏សំខាន់បំផុត សម្រាប់ឱ្យមានការ ទទួលស្គាល់សហគមន៍ខ្មែរ នៅហ្វីឡាដែលហ្វៀនេះ ហើយនៅបីឆ្នាំចុងក្រោយនេះ មោទនភាពនៃសហគមន៍មួយដែលធ្លាប់រុងរឿងបានងើបឡើងវិញ ជាមួយនឹងកំណើតនៃមន្ទីរសិល្បៈខ្មែរ - វិទ្យុខ្មែរ និងកាសែតខ្មែរ ឥឡូវភោជនីយដ្ឋានខ្មែរ អតីតយុទ្ធជនខ្មែរ វត្តខ្មែរ តំណាងខ្មែរនៅសាលាក្រុង ។ល។

តទៅទំព័រទី ៣




បាតុកម្មសិស្សអាស៊ីនៅសាលាហ្វីឡា

# វិបត្តិនៅវិទ្យាល័យហ្វីឡាខាងត្បូង (ត)

ដោយ : ពិន សំខុន

•••សិស្សនៅវិទ្យាល័យ ហ្វីឡាខាងត្បូង ជាង ១០នាក់ ដែលដឹកនាំកូដកម្មមិនចូលរៀនតាំងពីរអាទិត្យ ហើយនោះ បានប្រកាសបញ្ចប់កូដកម្មរបស់ក្រុមសិស្សអាស៊ី បន្ទាប់ពីជួបពិភាក្សាជាមួយនាយកក្រសួងអប់រំ អាកលីន អាក់ម៉ាន់ (ARLENE ACKERMAN ) និងអ្នកគ្រប់គ្រងក្រសួងអប់រំឯទៀតៗ កាលពីថ្ងៃអង្គារ ទី១៦ ធ្នូ ២០០៩ រួចមក ។ នាយកសាលា និងនាយកក្រសួង បានសន្យាធានាសុវត្ថិភាពជូនដល់សិស្សជាង ៥០នាក់ ដែលបាននាំគ្នាធ្វើកូដកម្ម ដោយសនិយាយថា " យើងនឹកដល់អ្នក... យើងចង់ឱ្យអ្នកត្រឡប់មកសាលាវិញ... យើងនឹងជួយគ្រប់យ៉ាងទាំងអស់... " ។

កូដកម្មនេះ បានកើតឡើងនៅថ្ងៃទី ៣ ខែធ្នូ មុននេះ ដោយក្រុសសិស្សអាហ្វ្រិកាំង-អាមេរិកាំង ប្រដេញវាយតប់សិស្សអាស៊ី នៅក្នុងបរិវេណ និងក្រៅវិទ្យាល័យហ្វីឡាខាងត្បូង អស់តយៈពេលមួយថ្ងៃ បណ្តាលឱ្យមានរបួសប្រមាណ ២០នាក់ ហើយដឹកមន្ទីរពេទ្យ ៧នាក់ ។ ក្រុមសិស្សអាស៊ីបានប្រជុំគ្នា ប្រកាសផ្តើមកូដកម្មមិនចូលរៀន រហូតដល់ក្រសួង និងវិទ្យាល័យផ្តល់កិច្ចការពារគ្រប់គ្រាន់ដល់ពួកគេ ដោយថ្លែងថា " វិទ្យាល័យហ្វីឡាខាងត្បូង ពុំផ្តល់សុវត្ថិភាពឱ្យពួកយើងទេ - យើងត្រូវគេតំគួន ដោយសារតែយើងជាពួកអាស៊ី អន្តោប្រវេសន៍-រៀងរាល់ថ្ងៃយើងរទូវគេជេ និងធ្វើបាប ។ យើងឈឺចាប់ណាស់ នៅពេលត្រូវសិស្សឯទៀត វាយធ្វើបាបយើង តែយើងឈឺចាប់រឹតតែខ្លាំង នៅពេលបុគ្គលិកវិទ្យាល័យមិនអើពើ មិនទទួលស្គាល់ ឬក៏លាក់បំបាំងការវាយ ដោយប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ស្បែក មកលើយើង ។ យើងសម្រេចធ្វើកូដកម្មប្រឆាំងសាលាយើង ដោយយើងចង់ឱ្យមានការធានាសុវត្ថិភាពយ៉ាងណាដល់ពួកយើង - សិស្សស្ទើរតែទាំងអស់នៅវិទ្យាល័យហ្វីឡាខាងត្បូង មានអាស៊ី, អាហ្វ្រិកឡាទីណូ និងពួកស្បែកស ស្ថិតនៅក្នុងសភាពដូចយើងដូច្នោះដែរ ។ ទាំងអស់គ្មានសាកល្បង

តទៅទំព័រទី ១៥





## ពិធីលៀងភោជនាហារ រាត្រីចូលឆ្នាំ សួស្តីឆ្នាំ 2010

សូមអញ្ជើញក្រុមគ្រួសារនឹងប្រិយមិត្តទាំងអស់មកជប់លៀងលាឆ្នាំប្រកបដោយការងារដ៏ទៀយហាត់ ហើយនឹងសម្លឹងឆ្ពោះទៅឆ្នាំ ២០១០ ដោយមេត្រី សង្ឃឹមជាមួយគ្នា

រៀបចំដោយសារព័ត៌មានខ្មែរប៉ុស្តិ៍

នៅថ្ងៃ : ទី០១ ខែ មករា ឆ្នាំ ២០១០

ពីម៉ោង ៦:០០ ដល់ ១២ អធ្រាត

នៅ : ភោជនីយដ្ឋានខ្មែរ កាវី

320 W. Oregon Avenue.
Philadelphia, Pa 19148

អញ្ជើញពិសារម្ហូបខ្មែរសុទ្ធសាធ ចំអិនដោយចុងភៅមានបទពិសោធន៍ច្រើនឆ្នាំ ស្តាប់ភ្លេង "តន្ត្រីវ៉ាយោ" រាំកំសាន្ត និងកំសាន្តឆាកល្ខោន មានរង្វាន់ប្អូរគ្មា. មានឆ្នោតវត្ថុឥតគិតថ្លៃ នឹងរង្វាន់ផ្សេងៗទៀត តម្លៃចូលកំសាន្ត $40

HOSTED BY:
ខ្មែរប៉ុស្តិ៍ ឆ្នេរខាងកើត
THE KHMER POST
EAST COAST
The Cambodian-American Biweekly News

ឥឡូវនេះលោកអ្នកអាចផ្តើមទូរស័ព្ទទៅទិញកន្លែងអង្គុយ :
267-253-3947 ឬ 267-254-8758
ជាមួយនឹងខ្មែរប៉ុស្តិ៍ លោកអ្នកច្រាកដជាពេញចិត្ត និងជួបតែភាពរីករាយមិនខានឡើយ !

# Yoo's Auto Service and Collision

## យូ បំរើសេវារថយន្ត
នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច

ផ្នែកជាងម៉ាស៊ីន

- Check Engine Light Diagnostic
- Electronic Wheel Alignment
- Certified Enhanced Emission
- Inspection & Repairs
- Muffler & More

FREE ESTIMATES

យើងនឹងជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុតតាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។

**COUPON**
$10 OFF TOWARD EMISSION AND STATE INSPECTION

ផ្នែកជួសជុលតួរថយន្ត

- Expert Body Work
- Fender & Paint Work
- Frame Straightening
- Insurance Specialists




ទូរស័ព្ទរក SAM 215-457-7777 ឬ 215-457-7779, Fax-215-457-7475
189 W. Duncannon Ave. Phila., PA 19120





777-300ER

## ពីញូយ៉កទៅតាយប៉េ
## ហោះ ៤ ជើងក្នុងមួយសប្តាហ៍

ចាប់ផ្តើមហោះហើរពីថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៥ //
"អេវ៉ា" អាកាសចរមានសេវា ញូយ៉ក-តាយប៉េ នៅថ្ងៃច័ន្ទ ថ្ងៃពុធ-ថ្ងៃព្រហស្បត្តិ៍ និងថ្ងៃសៅរ៍...ធ្វើឱ្យដំណើរទៅកាន់ទ្វីបអាស៊ីមានភាពប្រសើរគ្មានពេលណាដូចយន្តហោះថ្មីធុន ជាមួយនឹងបន្ទប់ធំទូលាយ និងមានបច្ចេកទេសទំនើបចែកជាថ្នាក់អ្នកដំណើរទី១ ថ្នាក់អ្នកដឹកនាំ និងថ្នាក់អ្នកដំណើរមធ្យម មានបន្ទប់បុគ្គលិកគួរឱ្យចូលចិត្ត សម្រាប់បង្កើនបរិយាកាសសម្រាកកាយ និងកក់ក្តៅក្នុងចិត្ត ធ្វើឱ្យដំណើរលោកអ្នករីកតែរីករាយប្រសើរឡើង ។






EVA AIR

EVA Wings – Booking, Buying and Bonuses just a click away at www.evaair.com
Contact us at our local service hotline: 800-695-1188

# កូនខ្មែរដំបូងគេក្នុងប្រវត្តិសាស្ត្រជាបេក្ខជនសភាតំណាងរាស្ត្រអាមេរិក

**ក្រុងខ្មែរ ឡុងប៊ិច : មាជ សុវណ្ណារ៉ា**

•ថ្លែងទៅកាន់មនុស្សម្នាក្នុងពិធីរៃអង្គាសប្រាក់ដើម្បីគាំទ្របេក្ខភាពជាអ្នកតំណាងរាស្ត្រអាមេរិក មាស សែម បានបង្ហើបសំដីរបស់លោកដោយភាពញញឹមថា "គាំទ្រខ្ញុំ គឺគាំទ្រ ខ្មែរទាំងអស់គ្នា ដើម្បីនាំសំឡេងខ្មែរ និងកិត្តិយសជាតិខ្មែរនៅឯវិមានរដ្ឋសភាអាមេរិកក្នុងការស្វែងរកការគាំទ្រ និងការចាប់អារម្មណ៍ដោយមានការយកចិត្តទុកដាក់ពីរដ្ឋាភិបាលអាមេរិក សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងដំណោះស្រាយបញ្ហាផ្សេងៗនៅតាមសហគមន៍ខ្មែរយើងនានាក្នុងទូទាំងសហរដ្ឋអាមេរិក" ។ មាស សែម ថ្លែងបន្តថា "ខ្ញុំរំភើប ហើយមានកម្លាំងចិត្តនៅពេលឃើញបងប្អូនខ្មែរយើងចេះជួយគាំទ្រគ្នា ដូចជារាត្រីនេះ ( ថ្ងៃធ្វើពិធី 4 ធ្នូ 2009 ) ដែលបាននាំគ្នាមកជួយគាំទ្រខ្ញុំទាំងការជួយលើកទឹកចិត្តទាំងការជួយទំនុកបម្រុងផ្នែកថវិកាដល់ការជំរុញឱ្យខ្ញុំជាកូនខ្មែរធ្វើដំណើរឆ្ពោះទៅកាន់វិមានរដ្ឋសភាជាអ្នកតំណាងរាស្ត្រអាមេរិក និងជាតំណាងខ្មែរផងនោះ" ។

មាស សែម គឺជាបេក្ខជនតំណាងរាស្ត្រអាមេរិកប្រចាំរដ្ឋ ម៉ាហ្សាឈូសេត ពីគណបក្សសាធារណៈរដ្ឋក្នុងការត្រៀមខ្លួនឈរឈ្មោះឱ្យពលរដ្ឋអាមេរិកាំងបោះឆ្នោតឱ្យនៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ2010 ។

ក្នុងពិធីជួបជុំដើម្បីរៃអង្គាសថវិកាគាំទ្រដល់បេក្ខជនតំណាងរាស្ត្រអាមេរិករបស់ មាស សែម នាថ្ងៃទី4 ធ្នូ ឆ្នាំ 2009 គេសង្កេតឃើញបងប្អូនខ្មែរជាងមួយរយនាក់ មកពីគ្រប់ទិសទីក្នុងរដ្ឋ California ជួបជុំគ្នាដើម្បីផ្តល់កម្លាំងចិត្តកម្លាំងកាយ រួមទាំងការបរិច្ចាគវិភាគទានដល់បេក្ខជនកូនខ្មែរមួយរូបនេះ ។ ពិធីបានចាប់ផ្តើមពីម៉ោង7យប់ទៅ ដោយមានការគោរពភ្លេងជាតិខ្មែរ និងអាមេរិកព្រះសង្ឃសូត្រជ័យន្តោ ក្រុមរបាំខ្មែររាំពត់ពេនជូនពរពិធីជាដើម ។

នៅក្នុងការថ្លែងសន្ទរកថា បេក្ខជនសភាតំណាងរាស្ត្រអាមេរិក មាស សែម បានថ្លែងថា យើងអាចកសាងបាននូវទំនុកចិត្តរវាងគ្នា និងគ្នាដោយការជឿទុកចិត្តគ្នានោះ ជនជាតិខ្មែរ-អាមេរិកាំងនឹងមិនរស់នៅក្នុងភាពឯកោ ឬក្នុងភាពភ័យខ្លាចទៀតទេ ពីព្រោះយើងបានរួបរួមគ្នា ធ្វើជាមួយគ្នាទទួលជោគជ័យជាមួយគ្នា និងការចែករំលែកផលជាមួយគ្នានាពេលអនាគតនូវចក្ខុវិស័យនៃការផ្លាស់ប្តូរគោលគំនិតជាសំខាន់ គឺនៅទីនេះក្រុង Long Beach មាន Cambodia Town ហើយ ដែលនឹងមាន Khmer Town **តទៅទំព័រទី...**



បេក្ខជន មាស សែម (រូបថតខ្មែរប៉ុស្តិ៍- វ៉ាន់ថា ឯល)

( តមកពីទំព័រទី ០១)

## សមាគមខ្មែរមានអាយុ...

ដាណាលី និស្សិតផ្នែកសារព័ត៌មាននៃសកលវិទ្យាល័យ "ថែមពិល" បានធ្វើសេចក្តីរាយការណ៍ឱ្យ ខ្មែរប៉ុស្តិ៍ ពីខួប ៣០ឆ្នាំរបស់សមាគមខ្មែរដូចតទៅ :



Author : Dannaly Sam

CAGP Recognizes the Past Thirty Years

The Cambodian Association of Greater Philadelphia (CAGP) hosted a celebratory event on late Friday night of December 18th at the Khmer Art Gallery. The event not only celebrated Cambodian culture with dances and performances that captured the Khmer people's voices in light of the past thirty years, but the Association's members were also honored with awards for their service to the Cambodian-American community. The night's performances and speeches ranged in different formats that included traditional Khmer music and dance, a speech given by Dr. Ben Kiernan, a recounting of Anida Yoeu Ali's experience during the Khmer Rouge years, a performance by Linda Son that brought forth the pain of losing a loved one, and entertainment by the AZI Fellas whose main message in their performance was to "strive on."

In a speech given by Rorng Sorn before the awards ceremony, she clearly stated the event's main message with the words, *CONTINUED ON PAGE 16*


**The Khmer Post Directory**

**East Coast Publication**

Regional Editor : Pin Samkhon

Email : pinsamkhon@gmail.com

**Writers** : Mam Yin, Kim Phean, Dannaly Sam

**Advertising**

**Marketing Manager : Sabane Thach**

**Phone : 267-253-3947**

**Email : sabane.thach@gmail.com**



**VIP Auto Center**

**បំរើសេវារថយន្ត**

**នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច**

■Mechanic Service ■Body Repair ■State Inspection ■Towing Service

យើងនឹងជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត
តាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។



**ផ្នែកជាងម៉ាស៊ីន**

Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
Inspection & Repairs
Muffler & More

**ផ្នែកជួសជុលតួរថយន្ត**

Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists

601W. Fisher Ave. Phila., PA 19120
Tel : 215-455-9999/215-329-4444/ Fax : 215-455-3757

# A.B.C MONEY TRANSACTION, INC

# ក្រុមហ៊ុនផ្ញើប្រាក់ A.B.C

## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ



| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកំម្រៃ | $4.50 | $5.50 |
| $200 | យកកំម្រៃ | $9.00 | $11.00 |
| $300 | យកកំម្រៃ | $13.50 | $16.50 |
| $500 | យកកំម្រៃ | $16.00 | $17.00 |
| $1000 | យកកំម្រៃ | $25.00 | $26.00 |
| $1500 | យកកំម្រៃ | $35.00 | $36.00 |
| $2000 | យកកំម្រៃ | $42.00 | $43.00 |
| $2200 | យកកំម្រៃ | $46.00 | $47.00 |

សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

**ABC MONEY TRANSATION ,INC.**

8 locations to serve you in Virginia

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

**ARIZONA**
- 4215 N 19th Ave. . Tel : 602.266.6744

**GEOERGIA**
- 4897 Buford Hwy. Ste. 202. Tel: 770.457.7888

**ILLINOIS**
- 4871 N. Broadway . Tel :773.989.7332

**MASSACHUSETTE**
- 996 Dorchester Ave. Tel:617.825.9380
- 1365-1377 Dorchester Ave. -Ste.4,Froor 1 .Tel : 617.265.4600

**MINNESOTA**
- 2718 Nicollet Ave . S.- Ste. 102 B
- Tel : 612.871.4731
- 6350 Brooklyn Blvd . Tel : 763.503.3947

**NORTH CAROLINA**
- 3000 Central Ave. Ste . #9 . Tel : 704-532-4420

**OREGON**
- 6908 N.E. Sandy Blvd . Tel : 503.281.8088

**PHILADFELPHIA**
- 5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794
- 571 Adams Ave . Ave.#4 . Tel : 215.342.6623

**TEXAS**
- 1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461
- 2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817
- 5302 E . Belknap St.- Ste.D6 . Tel : 817.831.4836
- 3538 W . Walnut St. Tel : 972.272.2253
- 11205 Bellaire Blvd . Tel : 281.561.6600
- 10909 Scarsdale Blvd . Tel : 281.481.2700
- 13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

**WASHINTON STATE**
- 766 S.38th St,. Tel : 253.475.2847
- 3818 S.Graham St.-Ste. C Tel : 206.721.2070

Office : 714-590-8740 Fax : 714-590-8776
Cell: 714-603-3509 Toll Free : 1-877-939-0110

## ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

## ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

(តមកពីទំព័រទី ០៣)

# កូនខ្មែរដំបូងគេក្នុងប្រវត្តិសាស្ត្រ...

នៅទីក្រុង Lowell រដ្ឋម៉ាហ្សាឈូសេត នាពេលខាងមុខ ។ យើងត្រូវមានសម្លេងជាតំណាងរបស់ខ្មែរ-អាមេរិកាំងនៅគ្រប់រចនាសម្ព័ន្ធរដ្ឋាភិបាល តាំងពីថ្នាក់ក្រុង ថ្នាក់រដ្ឋ និងថ្នាក់សហព័ន្ធ ។ ការផ្តល់ការងារ និងឱកាសកសាងសេដ្ឋកិច្ចសម្រាប់ពលរដ្ឋខ្មែរ-អាមេរិកាំង ជាមួយនឹងការបង្កើនគុណភាព និងសេវាកម្មផ្នែកវិស័យ សិក្សាធិការសម្រាប់កូនខ្មែរក្នុងសង្គមខ្មែរ-អាមេរិកាំង ដោយធ្វើយ៉ាងណាឱ្យកូនខ្មែរ ទទួលបានការសិក្សាយ៉ាងហោចណាស់បានបញ្ចប់ថ្នាក់មធ្យមសិក្សានៅវិទ្យាល័យ ។ ដោយធ្វើសកម្មភាពអប់រំក្នុងការកាត់បន្ថយអត្រាមានផ្ទៃពោះនៃយុវនារីតិជន ។


មាស សែម ថ្លែងទៅកាន់ភ្ញៀវដែលចូលរួមគាំទ្របេក្ខភាពរបស់ខ្លួន (រូបថតខ្មែរប៉ុស្តិ៍- វ៉ាន់ថា ឯល)

មាស សែម ថ្លែងយ៉ាងមុតមាំថា **"ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងមានមោទនភាពដើម្បីបង្ហាញប្រាប់បងប្អូនថា ខ្លួនខ្ញុំ គឺជាជនជាតិខ្មែរ-អាមេរិកាំង ដំបូងក្នុងប្រវត្តិសាស្ត្រ ដែលបានឈរឈ្មោះជាបេក្ខជនសភាតំណាងរាស្ត្រអាមេរិកនៅក្នុងមណ្ឌលទី5នៃរដ្ឋម៉ាហ្សាឈូសេត ខ្ញុំសង្ឃឹមថា បេក្ខភាពរបស់ខ្ញុំ គឺជាភាពជោគជ័យរបស់ខ្មែរ និងជាជោគជ័យរបស់អ្នករាល់គ្នា ហើយក៏ជាជ័យជំនះរបស់យើងគ្រប់គ្នាជាជនជាតិខ្មែរ-អាមេរិកាំងដែលរស់នៅលើទឹកដីអាមេរិក ។ ខ្ញុំនឹងជាតំណាងរបស់អ្នករាល់គ្នានៅក្នុងសភាអាមេរិកាំង... ខ្ញុំនឹងខិតខំធ្វើការដើម្បីផលប្រយោជន៍អ្នករាល់គ្នា... ហើយសំឡេងរបស់ជនជាតិខ្មែរយើងនឹងមិនត្រូវបាននរណាម្នាក់ធ្វើមិនដឹងមិនឮបានទៀតឡើយ"** ។

មាស សែម បានអំពាវនាវទៅដល់បងប្អូនខ្មែរជាទូទៅក្នុងន័យយ៉ាងដូច្នេះថា "ដើម្បីឱ្យខ្ញុំអាចធ្វើការបម្រើអ្នកទាំងអស់គ្នា និងដើម្បីឱ្យរូបខ្ញុំក្លាយទៅជាតំណាងពេញសិទ្ធិរបស់អ្នកទាំងអស់គ្នា គឺខ្ញុំត្រូវការការចូលរួម និងជ្រោមជ្រែងពី សំណាក់បងប្អូនទាំងអស់គ្នា ដោយខ្ញុំចង់ឮពីសម្លេង កង្វល់ និងសេចក្តីត្រូវការរបស់បងប្អូន ។

អ្នកនយោបាយជើងចាស់ ខ្មែរ-អាមេរិកាំង ម្នាក់ដែលបាន ចូលនិវត្តន៍ កាលពី5ឆ្នាំមុននៅ តំបន់ Washington, D.C មិនចង់បញ្ចេញឈ្មោះបានប្រាប់ ខ្មែរប៉ុស្តិ៍ឱ្យដឹងថា ការគាំទ្រថវិកា និងស្មារតីចំពោះ កូនខ្មែរជំនាន់ក្រោយ ដែលជាប្រវត្តិសាស្ត្រទី1របស់ជនជាតិខ្មែរ-អាមេរិកាំង គឺចាំបាច់ណាស់ពីយើងជាពលរដ្ឋខ្មែរ-អាមេរិកាំងទាំងអស់គ្នាត្រូវជំរុញសាមគ្គី និងគាំទ្រដើម្បីប្រយោជន៍ខ្មែរទាំងមូល មិនមែនដើម្បីប្រយោជន៍បុគ្គល សែម មាស ម្នាក់ឯងនោះទេ ។ ដោយយើងកុំទាន់គិតបែងចែកខ្មែរនេះ... ខ្មែរនោះ... កើត ឬមិនកើត ពោល គឺធ្វើយ៉ាងណាឱ្យពាក្យថា ខ្មែរ... ជនជាតិខ្មែរ... លេចធ្លោមានកិត្តិយស មានសំឡេងក្នុងអំណាចរដ្ឋាភិបាលអាមេរិកាំងសិន ។

អ្នកនយោបាយជើងចាស់រូបនេះបានបន្តប្រសាសន៍ថា ការជួយជ្រោមជ្រែងសម្រាប់យុទ្ធនាការរបស់ មាស សែម ពីបងប្អូនខ្មែរ មិនថាក្នុង ឬក្រៅរដ្ឋ និងបណ្តាជនជាតិអាស៊ី-អាមេរិកាំងផ្សេងទៀត គឺជាគន្លឹះនាំឱ្យរូបគេ (មាស សែម) នឹងឈ្នះឆ្នោត ។



បងប្អូនខ្មែរដែលបានចូលរួមក្នុងពិធីនោះ បាននាំគ្នាឆ្លើយនឹងសំណួរខ្មែរប៉ុស្តិ៍ឱ្យដឹងថា ពួកគេរីករាយគាំទ្របេក្ខជន មាស សែម ព្រោះចង់ឃើញកូនខ្មែរជំនាន់ក្រោយជួយលើកស្ទួយជាតិខ្មែរឱ្យមានមុខមាត់កិត្តិយសឱ្យបានប្រពៃនៅក្នុងរដ្ឋាភិបាល រដ្ឋសភារបស់ប្រទេសអាមេរិក ដើម្បីកុំឱ្យខ្មាសជាតិសាសន៍គេដែលជាជនជាតិអាស៊ីដូចគ្នា ហើយចំណាកស្រុកដូចគ្នា ពួកគេខំប្រឹងរហូតបានដល់ធ្វើការធំៗនៅសេតវិមានរដ្ឋសភា មានតំណាងរាស្ត្រ ព្រឹទ្ធសភា ដូចជា ជនជាតិយួន ចិន ម៉ុង ជាដើម ។ ដូច្នេះសូមឱ្យខ្មែរ-អាមេរិកាំងរួបរួមគ្នាជួយគាំទ្រគ្នាក្នុងនាមខ្មែរតែមួយ ជាតិតែមួយ ទោះបីការជួយជាជំនួយតិចក្តី ឬច្រើនក្តី ។

ក្នុងឱកាសនោះបេក្ខជន មាស សែម បានដាក់ការសន្យាថា "នៅពេលខ្ញុំក្លាយជាអ្នកតំណាងរាស្ត្រសភាអាមេរិកាំង ខ្ញុំនឹងខិតខំធ្វើការកែទម្រង់វិស័យសុខភាព ដែលជាតម្រូវការចាំបាច់ទាមទារឱ្យមានដំណើរការកំណែទម្រង់ពិតប្រាកដ ពោល គឺមិនមែនអ្វីដែលរដ្ឋសភា និងប្រធានាធិបតីបាននឹងកំពុងធ្វើនាពេលសព្វថ្ងៃនេះទេ ។ ដូចជាដំណោះស្រាយពិតប្រាកដអំពីតម្លៃនៃការថែទាំសុខភាព ការធានារ៉ាប់រងផ្នែកសុខភាពដែលអាចជួយដល់អ្នកក្រីក្រគ្រប់គ្នានៅទូទាំងប្រទេសអាមេរិក និងការបង្ហាញឱ្យឃើញនូវការប្រកួតប្រជែងនៃឧស្សាហកម្មថែទាំសុខភាព ដែលជាគម្រោងច្បាស់លាស់ និងតម្លៃថោក" ។

មាស សែម បានប្រមើលមើលក្នុងចំណាត់ការឱ្យដឹងថា អត្រាអ្នកអត់ការងារធ្វើចំនួន 10% នៅទូទាំងប្រទេស ព្រោះតែការធ្លាក់ចុះនៃវិបត្តិ សេដ្ឋកិច្ចនៅអាមេរិក និងពិភពលោកនោះ ។ មាស សែម បានដាក់ការសង្ឃឹមថា យើងពិតជាអាចដោះស្រាយបានពីវិបត្តិនេះ ដោយផ្តល់នូវការលើកទឹកចិត្តចំពោះការបង់ពន្ធ និងកញ្ចប់ថវិកាសម្រាប់វិស័យពាណិជ្ជកម្មខ្នាតតូចៗ ។ ដោយយើងមិនអាចអនុវត្តការប្រមូលពន្ធដូចរដ្ឋបាលលោកប្រធានធិបតី Obama និងសភាដែលត្រួតត្រាដោយពួកបក្សប្រជាធិបតេយ្យនាពេលបច្ចុប្បន្ននេះទេ ។ ជាមួយនឹងកំណែទម្រង់អប់រំបញ្ហាអន្តោប្រវេសន៍ទាក់ទងនឹងការបញ្ជូនកូនខ្មែរត្រឡប់ទៅកម្ពុជាវិញ និងការយកចិត្តទុកដាក់សម្រាប់មនុស្សចាស់ជាខ្មែរ-អាមេរិកាំងជាដើម ។

ជុំវិញបញ្ហានៃការឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រសភាអាមេរិករបស់ មាស សែម មតិពីមជ្ឈដ្ឋានមហាជនមួយចំនួនបានមើលឃើញថា បងប្អូនខ្មែរនៅអាមេរិកមានចំនួនមិនជាច្រើនលើសលុបឡើយ ដែលបានក្លាយខ្លួនទៅជាពលរដ្ឋអាមេរិកាំង ដោយភាគច្រើននៅកាន់ Green Card ។ ហើយអ្នកចូលសញ្ជាតិអាមេរិកនោះទៀត ហាក់មិនសូវចាប់អារម្មណ៍ពីរឿងនយោបាយនៅក្នុងសហរដ្ឋអាមេរិក ដោយមិនខ្វល់ខ្វាយពីបញ្ហាការទៅបោះឆ្នោត ដែលនេះជាបញ្ហា ? ហើយធ្វើឱ្យសំឡេងខ្មែរយើងបែរជាមានតិចទៅវិញ ក្នុងអត្រាស្ថិតិចុះឈ្មោះបោះឆ្នោត ។ ក្នុងខណៈដែលខ្មែររស់នៅសហរដ្ឋអាមេរិកមានជាង 40ម៉ឺននាក់ ។ ដូច្នេះក្នុងនាមសហគមន៍ខ្មែរនីមួយៗ ត្រូវគិតពីបញ្ហាចូលសញ្ជាតិការយល់ដឹងពីសារៈសំខាន់ពីនយោបាយអាមេរិក ទៅនឹងការបោះឆ្នោត ដោយមិនត្រូវលើកយកបញ្ហានយោបាយនៅកម្ពុជា មកប្រៀបប្រដូចទៅនឹងសង្គមអាមេរិកនោះទេ ៕


Ontime staffing HireSatisfaction™

បុគ្គលិកទាន់ពេល ជ្រើសរើសយ៉ាងពេញចិត្ត

POSITION AVAILABLE
នៅមានកន្លែងធ្វើការទំនេរ

PACKING ការងារវេចខ្ចប់
WAREHOUSE ការងារក្នុងឃ្លាំង
MANUFACTURING ការងារផលិត
MACHINE OPERATORS ការងារបញ្ជាម៉ាស៊ីន
ASSEMBLY ការងារផ្គុំគ្រឿង
GENERAL LABOR ការងារពលកម្មទូទៅ

COME IN AND APPLY TODAY
សូមអញ្ជើញមកដាក់ពាក្យសុំធ្វើការថ្ងៃនេះ

"Missa Bay" ជាក្រុមហ៊ុននាំមុខគេខាងម្ហូបអាហារ និងបន្លែស្រស់ នៅ ស.រ.អា ឥឡូវនេះ កំពុងរកអ្នកធ្វើការ៤០នាក់ ដើម្បីរៀបចំម្ហូប មិនចាំបាច់មានបទពិសោធន៍ ឬចំណេះខាងភាសាអង់គ្លេស ធ្វើការក្នុងបរិយាកាសសីតុណ្ហភាព ៤០°F ស្អាត ។ កំរៃផ្តើមពី ៨.៥ដុល្លារ ក្នុង១ម៉ោង កំរៃធ្វើលើសម៉ោង ១២.៧៥ ដុល្លារ ក្នុងមួយម៉ោង ធ្វើការលើស ៤០ ម៉ោង ក្នុងមួយអាទិត្យ ក្រុមហ៊ុនមានរថយន្តដឹកជញ្ជូនទៅកន្លែងធ្វើការ

**យើងទទួលពាក្យសុំធ្វើការនៅពីកន្លែងហើយគឺ :**

CHINATOWN: 207 N. 9TH STREET. PHILADELPHIA, PA 19107
TEL: 215-829-0188 (MON-FRIDAY)
9:00-5:00 P.M.
215-880-2724 (Sat & Sunday)
SOUTH PHILLY: 529 WASHINGTON AVE., PHILADELPHIA, PA
**សូមសួររក : ចាន់ សូម៉ាលី**
TEL: 267-608-0742 / 215-462-3508 (MON-FRIDAY)
267-238 2388 (Sat& Sunday)
OnTime Staffing, LLC

# HONG KONG

## SUPERMARKET

**FAMER´S BEST**






$1.69/can




3 for $10

**Newly Renovated.**
**Added new section .**
**Clean and Improved management !**

ទើបនឹងកែលំអរថ្មីឡើងវិញ
-បន្ថែមផ្នែកលក់ថ្មីទៀត
ហាងស្អាត ហើយបង្កើន
គុណភាពគ្រប់គ្រង

**Weekly Sale**

លក់ចុះថ្លៃរៀងរាល់សប្តាហ៍




$2.99/bag




$7.99



$2.99






$6.99/box




$1.29/can



$2.49/28oz



$2.49/bag




2 for $3



$4.99 / lb




$4.99

**OPEN 7 DAY**

**8:00 - 9:00**

571 ADAMS AVE.PHILADELPHIA,PA19120
Tel: 215-72801300 Fax: 215-728-1600

- ចំណាយ **$140**ដុល្លារ ទទួលបានអង្ករស្រូវស ២៥ ផោន
- ចំណាយ **$100**ដុល្លារ ទទួលបាននូវភេសជ្ជៈ ឬមីកញ្ចប់មួយប្រអប់(តម្លៃ**8.99**)
- ចំណាយ **$25** ដុល្លារទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

ហាងមាសរស្មី
215-271-2950
SUNSHINE JEWELRY INC
Fine Jewelry
Certified Diamond & Custom Design
702 Washington Ave . Phila.,PA 19147


# ប្រតិទិនប្រវត្តិសាស្ត្រ ខ្មែរប៉ុស្តិ៍ គ.ស 2010



ទូរស័ព្ទលេខ 267-254-8758 E-mail: khmerpostusa@gmail.com


Danny's Café
Tel: 215.467.4082
Foods & Hoagies
1. Beef Stew Serve with Bread
2. Curry Chicken Serve with Bread
3. Curry Beef Saramann Serve with Bread
4. Meatball Soup Serve with Bread
5. Mi Siam
1730 Snyder Ave.Philadelphia, PA 19145
Mon-Fri:7am-7pm Saturday:9 am-8 pm / Sunday : CLOSED



ភោជនីយដ្ឋានខ្មែរ
Kavei
CAMBODIAN RESTAURANT
Authentic Khmer • Thai • Lao • Vietnamese Pho
320 W OREGON AVENUE
(OREGON MARKET,SOUTH PHILLY)
215-952-6688
OPEN 7 DAYS A WEEK
9am-10pm


## មករា 1 JANUARY

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| | | | | | 1 | 2 |
| 3 | 4 | 5 | 6 | 7 | 8 | 9 |
| 10 | 11 | 12 | 13 | 14 | 15 | 16 |
| 17 | 18 | 19 | 20 | 21 | 22 | 23 |
| 24/31 | 25 | 26 | 27 | 28 | 29 | 30 |

## កុម្ភៈ 2 FEBRUARY

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 |
| 7 | 8 | 9 | 10 | 11 | 12 | 13 |
| 14 | 15 | 16 | 17 | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 |
| 28 | | | | | | |

## មិនា 3 MARCH

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 |
| 7 | 8 | 9 | 10 | 11 | 12 | 13 |
| 14 | 15 | 16 | 17 | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 |
| 28 | 29 | 30 | 31 | | | |

## លំដាប់កាលប្រវត្តិសាស្ត្រខ្មែរ

សម័យខ្មែរមែន ឆ្នាំ-៤០០០ | ឆ្នាំ-១០០មុនគ.ស | ផ្សព្វផ្សាយឥទ្ធិពលឥណ្ឌា +100 ឆ្នាំ ក្រោយគ.ស | នគរហ្វូណន ឬនគរភ្នំ +200 ឆ្នាំ+500 | ចេនឡា +800 | សម័យកសាង សម័យអង្គរ

## មេសា 4 APRIL

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 |
| 4 | 5 | 6 | 7 | 8 | 9 | 10 |
| 11 | 12 | 13 | 14 | 15 | 16 | 17 |
| 18 | 19 | 20 | 21 | 22 | 23 | 24 |
| 25 | 26 | 27 | 28 | 29 | 30 | |

## ឧសភា 5 MAY

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| | | | | | | 1 |
| 2 | 3 | 4 | 5 | 6 | 7 | 8 |
| 9 | 10 | 11 | 12 | 13 | 14 | 15 |
| 16 | 17 | 18 | 19 | 20 | 21 | 22 |
| 23/30 | 24/31 | 25 | 26 | 27 | 28 | 29 |

## មិថុនា 6 JUNE

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 | 5 |
| 6 | 7 | 8 | 9 | 10 | 11 | 12 |
| 13 | 14 | 15 | 16 | 17 | 18 | 19 |
| 20 | 21 | 22 | 23 | 24 | 25 | 26 |
| 27 | 28 | 29 | 30 | | | |


PRIMERICA
A Citi Company

Chanthy Sek & Shawn Dougherty
Bus : 1-866-582-3172
E-mail : 8665823172@primerica.gosolo.com
Primerica Financial Services 1035 Virginia Dr., Ste 100H Ft. Washington, Pa 19034


## លំដាប់កាលប្រវត្តិសាស្ត្រខ្មែរ(ត)

កសាង ឆ្នាំ +900 សម័យអង្គរ | តំណាក់កាលរុងរឿង ឆ្នាំ +1100 | រុងរឿងបំផុត ឆ្នាំ .1200 | ដំណាក់កាលធ្លាក់ចុះ ឆ្នាំ +1400 សម័យអង្គរ | បោះបង់អង្គរ ឆ្នាំ +1430



The Perfect Front
Our locations :
I 76 W. Godfrey Ave. & Front St.Phila, PA 19120 Tel : (215) 548-0310
II 5730 Rising Sun Ave. Phila,PA 19120 Tel : (215) 342-4658
III 10105B Verree Rd Red Lion Phila, Pa 19116 Tel: 215-671-9553

ហាងថែរក្សាស្បែក លីង
215-467-4082
Lynn Skin Care
1730 Snyder Ave. Philadelphia, PA 19145

DR. TRUONG H. NGUYEN, M.S., D.O., P.C
5746 Rising Sun Ave. Phila, Pa 19120
Phone : (215) 904-8891
Fax : (215) 745-2290

TEL. (215) 744-8300
ADAMS DENTAL
GENERAL, COSMETIC, BRACES AND IMPLANT DENTISTRY
OFFICE HOURS: BY APPOINTMENT
801 ADAMS AVE. PHILADELPHIA, PA 19124

KHMER POST EAST COAST ADVERTISING, PLEASE CALL
267-253-3947 OR 267-254-8758
EMAIL: KHMERPOSTUSA@GMAIL.COM

រ៉ាត ជួសជុលរថយន្ត
510N.2ND ST., PHILADELPHIA, PA 19120.
TEL: (215) 329-2418
Fax : (215) 329-2419.
Rath Cell: (215) 431-6376



FOR ADVERTISING , CALL (267) 253-3947

# ប្រតិទិនប្រវត្តិសាស្ត្រ ខ្មែរប៉ុស្តិ៍ គ.ស 2010



ទូរស័ព្ទលេខ 267-254-8758 E-mail: khmerpostusa@gmail.com


ហាងមាសស៊ីនី
215-271-2950
SUNSHINE JEWELRY INC
Fine Jewelry
Certified Diamond & Custom Design
702 Washington Ave . Phila.,PA 19147

Danny's Café
Tel: 215.467.4082
Foods & Hoagies
1. Beef Stew Serve with Bread
2. Curry Chicken Serve with Bread
3. Curry Beef Saramann Serve with Bread
4. Meatball Soup Serve with Bread
5. Mi Siam
1730 Snyder Ave,Philadelphia, PA 19145
Mon-Fri: 7am-7pm Saturday: 9 am-8 pm / Sunday: CLOSED

ភោជនីយដ្ឋានខ្មែរ
Kavei
CAMBODIAN RESTAURANT
Authentic Khmer • Thai • Lao • Vietnamese Pho
320 W OREGON AVENUE
(OREGON MARKET,SOUTH PHILLY)
215-952-6688
OPEN 7 DAYS A WEEK
9am-10pm


## កក្កដា 7 JULY

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 |
| 4 | 5 | 6 | 7 | 8 | 9 | 10 |
| 11 | 12 | 13 | 14 | 15 | 16 | 17 |
| 18 | 19 | 20 | 21 | 22 | 23 | 24 |
| 25 | 26 | 27 | 28 | 29 | 30 | 31 |

## សីហា 8 AUGUST

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| 8 | 9 | 10 | 11 | 12 | 13 | 14 |
| 15 | 16 | 17 | 18 | 19 | 20 | 21 |
| 22 | 23 | 24 | 25 | 26 | 27 | 28 |
| 29 | 30 | 31 | | | | |

## កញ្ញា 9 SEPTEMBER

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 |
| 5 | 6 | 7 | 8 | 9 | 10 | 11 |
| 12 | 13 | 14 | 15 | 16 | 17 | 18 |
| 19 | 20 | 21 | 22 | 23 | 24 | 25 |
| 26 | 27 | 28 | 29 | 30 | | |

លំដាប់កាលប្រវត្តិសាស្ត្រខ្មែរ (ក)

បោះបង់អង្គរ → សម័យចតុមុខ ឆ្នាំ +1500 → សម័យលង្វែក ឆ្នាំ+1600 → សម័យឧត្តុង្គ ឆ្នាំ+1800 → សម័យបារាំង ឆ្នាំ+1860

## តុលា 10 OCTOBER

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| | | | | | 1 | 2 |
| 3 | 4 | 5 | 6 | 7 | 8 | 9 |
| 10 | 11 | 12 | 13 | 14 | 15 | 16 |
| 17 | 18 | 19 | 20 | 21 | 22 | 23 |
| 24/31 | 25 | 26 | 27 | 28 | 29 | 30 |

## វិច្ឆិកា 11 NOVEMBER

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 |
| 7 | 8 | 9 | 10 | 11 | 12 | 13 |
| 14 | 15 | 16 | 17 | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 |
| 28 | 29 | 30 | | | | |

## ធ្នូ 12 DECEMBER

| Sunday | Monday | Tuesday | Wednesday | Thursday | Friday | Saturday |
|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 |
| 5 | 6 | 7 | 8 | 9 | 10 | 11 |
| 12 | 13 | 14 | 15 | 16 | 17 | 18 |
| 19 | 20 | 21 | 22 | 23 | 24 | 25 |
| 26 | 27 | 28 | 29 | 30 | 31 | |

លំដាប់កាលប្រវត្តិសាស្ត្រខ្មែរ (ខ និង ចប់)

បារាំង → សម័យសង្គមរាស្ត្រនិយម +1954 ឆ្នាំ +1970 → សម័យសាធារណរដ្ឋ +1975 → សម័យកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ +1979 → សម័យរដ្ឋកម្ពុជា → សម័យព្រះរាជាណាចក្រកម្ពុជា ឆ្នាំ+1993


PRIMERICA
A Citi Company

Chanthy Sek & Shawn Dougherty
Bus : 1-866-582-3172
E-mail : 8665823172@primerica.gosolo.com
Primerica Financial Services 1035 Virginia Dr., Ste 100H,Ft. Washington, Pa 19034



Our locations
76 W. Godfrey Ave. & Front St.Phila, PA 19120
Tel : (215) 548-0310
5730 Rising Sun Ave. Phila,PA 19120
Tel : (215) 342-4658
10105B Verree Rd Red Lion Phila, Pa 19116
Tel: 215-671-9553

215-467-4082
Lynn Skin Care
1730 Snyder Ave. Philadelphia, PA 19145

DR. TRUONG H. NGUYEN, M.S., D.O., P.C
5746 Rising Sun Ave. Phila, Pa 19120
Phone : (215) 904-6891

TEL. (215) 744-8300
ADAMS DENTAL
GENERAL, COSMETIC, BRACES AND IMPLANT DENTISTRY
Beautiful Teeth, Beautiful Smiles
OFFICE HOURS: BY APPOINTMENT
801 ADAMS AVE. PHILADELPHIA, PA 19124

KHMER POST EAST COAST ADVERTISING, PLEASE CALL
267-253-3947 OR 267-254-8758
EMAIL: KHMERPOSTUSA@GMAIL.COM

510 N.2ND ST., PHILADELPHIA, PA 19120.
TEL: (215) 329-2418
Fax : (215) 329-2419.
Rath Cell: (215) 431-6376

FOR ADVERTISING , CALL (267) 253-3947

ឌឹ ខេមបូឌា ដេលី
The Cambodia Daily

ជំណឹងប្រែសំរួលពីភាសាអង់គ្លេស អគ្គបទបានអនុញ្ញាតិឱ្យធ្វើការចុះផ្សាយដោយ ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី១៨ ខែធ្នូ ឆ្នាំ២០០៩

# Plight of Sex Workers Focus of Int'l Day

By Kuch Naren
THE CAMBODIA DAILY

Around 200 prostitutes, transgendered people and men who have sex with men gathered in Phnom Penh at the Russei Keo district offices of the NGO Women's Network for Unity yesterday to mark the first Cambodian celebration of the International Day to End Violence Against Sex Workers.

The group asked an audience, which included local authorities and police from six Phnom Penh districts, to end the arrests and intimidation of sex workers nationwide and also called on the National Assembly and other relevant government bodies to create laws protecting sex workers from arrest and violence.

"Please examine law-enforcement policies on anti-human trafficking and the sex trade, because they have created the potential for physical and sexual abuse by law enforcement [officials]," said Pek Sokchea, a member of the WNU steering committee, in a speech at the event.

She added that arrests should be made to help victims of true human trafficking, but that adults working voluntarily as prostitutes should not be arrested for plying their trade as a means to make a modest living for their families.

"Some women are the key pillars in earning income to feed their parents and children," Ms Sokchea said. "If they are caught and detained in shelters or forced to get vocational training, who will be responsible for the children and parents that need food to eat?"

Continued on page 16

# អ្នករកស៊ីផ្លូវភេទរាប់រយនាក់ ប្រារព្ធទិវាអន្តរជាតិបញ្ចប់អំពើហិង្សា

ដោយ : គុជ ណារ៉េន
The Cambodia dailly

●ស្រីពេស្យាមនុស្សខ្ទើយ និងមនុស្សប្រុសរួមភេទជាមួយនឹងប្រុសដូចគ្នាប្រមាណជា ២០០ នាក់ បានប្រមូលផ្តុំគ្នាក្នុងទីក្រុងភ្នំពេញនៅឯ-ការិយាល័យអង្គការក្រៅរដ្ឋាភិបាលបណ្តាញស្ត្រីរួបរួមគ្នា (WNU) ក្នុងខណ្ឌឫស្សីកែវ កាលពីម្សិលមិញដើម្បីប្រារព្ធទិវាអន្តរជាតិ ដើម្បីបញ្ចប់អំពើហិង្សាប្រឆាំងអ្នករកស៊ីផ្លូវភេទនៅក្នុងប្រទេសកម្ពុជាលើកទី១ ។

ក្រុមនេះ បានសុំអ្នកចូលរួមស្តាប់ដែលរាប់បញ្ចូលទាំងអាជ្ញាធរ និងប៉ូលិសមូលដ្ឋានមកពីខណ្ឌចំនួន៦ ក្នុងក្រុងភ្នំពេញឱ្យបញ្ចប់ការចាប់ខ្លួន និងការបំភិតបំភ័យអ្នករកស៊ីផ្លូវភេទទូទាំងប្រទេស ហើយក៏បានអំពាវនាវផងដែរដល់រដ្ឋសភា និងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធផ្សេងទៀតឱ្យបង្កើតច្បាប់ការពារក្រុមអ្នករកស៊ីផ្លូវភេទមិនឱ្យមានការចាប់ខ្លួន និងប្រើអំពើហិង្សាឡើយ ។

យោងតាម WNUឱ្យដឹងថា សារ និងរូបថតរបស់អ្នករកស៊ីផ្លូវភេទ ដែលត្រូវបានរំលោភបំពានព្យួរនៅតាមជញ្ជាំងនៃការិយាល័យ WNU និងមានការដាក់បញ្ចាំងស្លាយដែលពណ៌នាអំពីអ្នករកស៊ីផ្លូវភេទជាច្រើនដែលរងរបួសនៅលើផ្ទៃមុខ ខ្នង និងរាងកាយរបស់ពួកគេដែលតាមចោទថា ដោយសារអំពើឃោរឃៅរបស់ប៉ូលិស ។

លោកស្រី ពេក សុខជា សមាជិកគណៈកម្មាធិការនាយក WNU បានថ្លែងក្នុងសន្ទរកថាមួយនៅឯព្រឹត្តការណ៍នេះថា "សូមពិនិត្យមើលគោលនយោបាយអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស តទៅទំព័រទី ១៨

ការិយាល័យថែទាំសុខភាពគ្រួសារ
5746 Rising Sun Avenue, Philadelphia, Pa 19120
Phone: (215)904-6891 Fax: (215) 745-2290
DR. TRUONG H. NGUYEN, M.S., D.O., P.C
FAMILY MEDICINE – INTERNAL MEDICINE – OSTEOPATHIC MANIPULATIVE THERAPY
វេជ្ជបណ្ឌិតជំនាញខាងព្យាបាលជម្ងឺទឹកនោមផ្អែម_សរសៃបេះដូង_ពិនិត្យសុខភាពស្ត្រី(GYN)
_ពិនិត្យតម្រងនោម_ប្រព័ន្ធរំលាយអាហារ...
* ផ្នែកពិនិត្យសុខភាពជាប្រចាំ និងព្យាបាលជម្ងឺស្បែក....ឈឺក្បាលប្រកាំង, ឈឺសន្លាក់ដៃជើង
បញ្ជាក់សុខភាពសម្រាប់អាពាហ៍ពិពាហ៍, សម្រាប់ធ្វើដំណើរ និង សម្រាប់សាលារៀន
* ជាពិសេស : ទទួលព្យាបាលអ្នកគ្រោះថ្នាក់មានមុខរបួស ឬរអិលដួលនៅកន្លែងធ្វើការ
យើងណែនាំផ្តល់មេធាវីដែលមានបទពិសោធន៍ជាង ២០ ឆ្នាំ និងអ្នកបកប្រែភាសាជំនាញ មានខ្មែរ-ចិន-វៀតណាម
ជូនដោយឥតគិតថ្លៃ បើលោកអ្នកត្រូវការ :
* ធានាថា យើងធ្វើការបានលទ្ធផលឆាប់រហ័ស-លើសពីនេះ យើងរីករាយនឹងជួយដល់ភ្ញៀវណាដែល
មិនចេះនិយាយអង់គ្លេស ហើយចង់កំណត់ពេលទៅមន្ទីរពេទ្យ ឬចង់ប្តូរ
ក្រុមហ៊ុនធានាសុខភាព (Health Insurance)
* យើងទទួល មេឌីកេដ,មេឌីឃែ , និង អ៊ិនស្វរិន ស្ទើរតែទាំងអស់
និងគិតតម្លៃទាបជូនអ្នកដែលមិនមាន អ៊ិនស្វរិន ទៀតផង ។
ការិយាល័យបើកទ្វារ :៣
ថ្ងៃ ច័ន្ទ -អង្គារ-ពុធ- និង សុក្រ
ពីម៉ោង ៩ព្រឹកដល់១រសៀល
និងពីម៉ោង ៣ ដល់ ៧ ល្ងាច
បិទទ្វារ : ថ្ងៃ សៅរ៍ និងថ្ងៃអាទិត្យ និងព្រហស្បត្តិ៍

# ខ្មែរមានពូជ

*•••វាគ្មិនបួនរូប បានរៀបចំសិក្ខាសាលាមួយ នៅវត្តពោធិវង្ស នៃប្រទេសបារាំង ដើម្បីសិក្សារកឫសគល់ ដែលចេះតែនាំឱ្យខ្មែរ ឱនភាពផ្នែកស្មារតី តាំងពីបន្ទាប់សម័យអង្គរមក ។ ចំណោមអ្នកទាំងបួននោះ ក៏មានព្រះសង្ឃមួយអង្គផងដែរ ព្រះនាម ឌិន ភេន, លោកវេជ្ជបណ្ឌិត ស៊ុយ សៀងហេង, លោក ឌី ការ៉េត និង លោក ចាយ សេរីវុឌ្ឍ កាលពីថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០០៩ ។ វត្តពោធិវង្ស 101 BOULEVARD DELA REPUBLIQUE 77420 CHAPS SUN MARNE-FRANCE ។ ខ្មែរប៉ុស្តិ៍ បានលើកយកប្រយោគជាសេចក្តីរាយការណ៍របស់អ្នកទាំងបួន មកអានជាសណ្តាប់ ដោយយល់ថា ភាពឱនខ្សោយនៃស្មារតីខ្មែរ នាពេលនេះ នៅតែជាកង្វល់របស់សាធារណជនស្មើរគ្រប់ៗគ្នា ។ សូមអញ្ជើញអាននូវប្រយោគរបស់អ្នកទាំងបួន ដែលធ្វើវិភាគជូនសហគមន៍ខ្មែរជាច្រើននៅប្រទេសបារាំងដូចតទៅ :*



**លោក ស៊ុយ សៀងហេង**
**ឧមត្ថ រតនត្តយស្ស**

ពាក្យថា ពូជ គឺតំណជាតិកំណើត ឬវង្សត្រកូលរបស់មនុស្ស សត្វ ឬ រុក្ខជាតិ ។ ដូចនេះ មនុស្ស សត្វ រុក្ខជាតិ តែកើតមកហើយ ត្រូវមានពូជទាំងអស់ ។ តែខ្មែរមានទម្លាប់ប្រើថា មនុស្សមានពូជ គឺមនុស្សមានការអប់រំល្អ ។ លក្ខណៈខ្លះៗដែលល្អ ហើយដែលគួររាប់ថាជារបស់ខ្មែរយើងពិតៗ មាន ២ ពួក :

**ក. លក្ខណៈនៅក្នុងខ្លួន** និង **ខ. លក្ខណៈនៅក្រៅខ្លួន** ។

**ក. លក្ខណៈនៅក្នុងខ្លួន ដែលមានពីកំណើតមក**

តាមវិទ្យាសាស្ត្រ មនុស្សនៅលើផែនដីទាំងអស់មានពូជតែមួយទេ ។ អ្នកប្រាជ្ញខាងវត្ថុបុរាណ បានរកឃើញថា កាលពី ៤០.០០០[១] ឆ្នាំមុន មានមនុស្សដែលប្រកបដោយចរិតលក្ខណៈដូចយើងសព្វថ្ងៃ ១ ក្រុម បានរួចផុតពីស្លាប់រង្គាល នៅក្នុងទ្វីបអាហ្វ្រិក ក្រុងប្រទេសបុតស្វាណា ណាមីប៊ី

[១]-៤០.០០០ ឆ្នាំមុន បន្ទាប់ពីមហាភ្នំភ្លើងនៅ ប៊ិកនេអូ (ឥណ្ឌូនេស៊ី) ភ្លើងឆេះផែនដី ផ្សែងបាំងព្រះអាទិត្យ ជីវិតនៅលើដីស្លាប់ស្ទើរទាំងអស់ ។ ដំបូងដោយភ្លើងឆេះគ្មានសល់អ្វី សមុទ្ររីង បន្ទាប់មកដោយគ្មានពន្លឺថ្ងៃ អាកាសត្រជាក់ ។ ក្នុងលោកទាំងមូល ពូជមនុស្ស១ក្រុម មិនដល់ ១.០០០ នាក់ទេ ដែលរួចជីវិតពីមហន្តរាយនេះ គឺជនដែលនៅឆ្ងាយពីភ្នំភ្លើង ក្នុងទ្វីបអាហ្វ្រិក ។ ពូជផ្សេងៗទៀត ស្លាប់គ្មានសល់ ។ គេសន្និដ្ឋានថា សត្វដែលមានសណ្ឋានជាមនុស្សមានសតិអារម្មណ៍ស្រដៀងមនុស្ស តាំងតែពី ១៥០.០០០ ឆ្នាំ មកម្ល៉េះ ។ មានពូជជាច្រើន ។

និង អាហ្វ្រិកខាងត្បូង ។ ពួកមនុស្សដើម្បីនេះ បែកកូនបែកចៅ ក៏សាយភាយពេញពិភពលោក រហូតដល់សព្វថ្ងៃនេះ ។ ដោយឡែកអ្នកប្រាជ្ញខាងលោហិតវិជ្ជា បានសង្កេតឃើញថា ពពួកមនុស្សទាំងនោះ បន្ទាប់ពីបានឆ្លងកាត់ទ្វីប កាត់មហាសាគរមក អ្នកខ្លះក៏រស់នៅក្នុងតំបន់ផ្សេងៗ ក្នុងតំបន់នីមួយៗ មនុស្សមានការប្រែប្រួល : មាឌធំ ធាត់ ស្គម សស្លាំង ខ្មៅ សម្បុរសណ្តែកបាយ តែរចនាសម្ព័ន្ធឈាមគេនៅតែដដែល គ្មានដូរទេ ។ តែក្រោយមក ចរិត លក្ខណៈឈាមក្នុងក្រុមមនុស្សខ្លះមានដុះខ្នែងប្លែកបន្តិច ឯកូនចៅសុទ្ធតែទទួលលក្ខណៈឈាមជាមរតកពីមាតាបិតា ដូនតា រហូតមកមិនដាច់ ។ នេះសឱ្យ ឃើញថា ពូជមនុស្សមានតែមួយគត់ ។

**លោហិតវិជ្ជា វប្បធម៌ និងជាតិសាសន៍**

លោហិតវិជ្ជា[២] និងវប្បធម៌ មានការទាក់ទង គ្នា គេចាប់ទទួលស្គាល់រឿងនេះ តាំងតែពីពេលដែលផ្តើមស្រាវជ្រាវរកជំពូកឈាមតាមភូមិសាស្ត្រជាលើកដំបូង ។ ដោយហេតុនេះ ទើបពួកលោហិតសាស្ត្របានរកឃើញជាតិ ហេមោគ្លោប៊ីន-អ៊ី Hémoglobine-E(Hb-E) នៅអាស៊ីអគ្នេយ៍ ក្នុងឈាមនៃជនជាតិខ្មែរ ។រីឯអ្នកប្រាជ្ញខាងបុរាណវត្ថុវិញ ក៏បានរកឃើញគំនរថ្មនៃប្រាសាទបាក់បែក និងប្រាសាទជំនាន់អង្គរនៅលើភូមិភាគដដែលនៅដែរ ។ គឺថាបើមានប្រាសាទជំនាន់អង្គរនៅត្រង់ណា

(តទៅលេខក្រោយ)



**ដោយ : ឌី ការ៉េត**

ខ្មែរមានពូជ គឺខ្មែរដែលកើតមកបានទទួលការអប់រំក្នុងគំនិតស្មារតី និងទំនៀមទម្លាប់ល្អនៃប្រជាជនខ្មែរ ។

ការស្រាវជ្រាវជាបន្ថែមថ្មីៗ ក្នុងប្រវត្តិសាស្ត្របានបង្ហាញថា ប្រជាជនខ្មែរ (និងប្រជាជន "មន") មានពូជពង្សបន្តពីប្រជាជនមួយ ហៅថា "មុនឌ:" (Monda) ដែលជាប្រជាជនរស់នៅប្រទេសឥណ្ឌាមុនគេបំផុត កាលពីជាង ៣០.០០០ ឆ្នាំ មុនគ្រិស្តសករាជ (គ.ស.) ។ ដោយមិនព្រមទទួលរងអំណាចនៃពួកឈ្លានពានបរទេសជាបន្តបន្ទាប់ ចាប់ពីម្ភៃឆ្នាំ ១០.០០០ មុន គ.ស. ប្រជាជនខ្មែរ បាននាំគ្នាចេញពីប្រទេសឥណ្ឌាបន្តិចម្តងៗ ហើយមកតាំងទីលំនៅនៅលើទឹកដីខ្លួនថ្មីសព្វថ្ងៃ ពីម្ភៃឆ្នាំ ៦.០០០ មុន គ.ស. ។ ពួក "មម" (Mom) ហៅថា "មន" (Mon) ដែលជាប់ខ្សែស្រឡាយនឹងខ្មែរ បានមកដល់ភូមា នៅម្ភៃឆ្នាំ ៣.០០០ មុន គ.ស. ហេតុនេះ ជនជាតិខ្មែរ បានមករស់នៅលើទឹកដីសព្វថ្ងៃមុន ពួកសៀម ពួកឡាវ ពួកយួន ពួកចាម ចំនួនរាប់ពាន់ឆ្នាំ ដោយមានភាសា មានវប្បធម៌ មានសាសនា មានចំណេះវិជ្ជារបស់ខ្លួនផ្ទាល់ ហើយបានសាងសង់ប្រទេសខ្លួន ហៅថា "ស្រុកខ្មែរ" យ៉ាងមាំមួនជាស្រេច ។ លុះចាប់ពីដើមឆ្នាំគ្រិស្តសតវត្សទី១ ទើបខ្មែរមានការទាក់ទងជាថ្មីជាមួយនឹងពួកជនជាតិឥណ្ឌា ដែលមានឥទ្ធិពលមកនៅដល់ប្រទេសម៉ាឡេ នាពេលនោះ ។

នៅក្នុងប្រវត្តិសាស្ត្រខ្មែរសព្វថ្ងៃ យើងបានដឹងខ្លះៗ តែអំពីសម័យ ហ្វូណន (នគរភ្នំ) សម័យចិនឡា សម័យអង្គរ ឬ កម្ពុជា ។ ប៉ុន្តែ នៅមុនសម័យ ហ្វូណន "ស្រុកខ្មែរ" ជារដ្ឋខ្លាំងពូកែមួយទៅហើយ ដែលគោរពលទ្ធិពិសេសមួយហៅថា "មត្តេយ្យកា" (មេ ម្តាយ ឬ ស្រ្តី ជាធំ ជាអ្នកដឹកនាំ - Le matriarcat) និងកាន់សាសនាមួយ ដែលគោរពបូជា "មេ បា" "នាងគង្ហីងព្រះធរណី និងព្រលឹងក្រពើ" "អ្នកតា" ជាអាទិ៍ ។ ជនជាតិខ្មែរ បានគោរពបូជាគុណបារមីទាំងនេះ នៅគ្រប់សម័យ ជាបន្តបន្ទាប់រហូត មកដល់សព្វថ្ងៃ ។ នេះសឱ្យឃើញថា រហូតមកដល់សព្វថ្ងៃ ប្រជាជនខ្មែរជា "ពូជ" តែមួយជានិច្ច ។

**ទេពកោសល្យនៃប្រជាជនខ្មែរ**

នៅក្នុងអតីតកាល គំនិតស្មារតី និងចំណេះវិជ្ជា មិនមែនបានកើតឡើង ក្នុងរយៈតែ ២០-៣០ឆ្នាំ ឬ ១០០ ឆ្នាំទេ ។ ប្រទេសឥណ្ឌា ឬចិន ដែលមានអារ្យធម៌ខ្ពស់ហើយ នៅពេលនោះ ក៏មិនដែលបានមកគ្រប់គ្រង ឬដឹកនាំប្រជាជនខ្មែរទេ ។ តែប្រជាជនមានទេពកោសល្យខ្ពស់ ដោយមានបង្កើតសម្រាប់ជាតិសាសន៍ខ្លួនឯងនូវប្រព័ន្ធមួយដឹកនាំសង្គម និងប្រទេស (គឺរបបមត្តេយ្យកា) សាសនាមួយរបស់ខ្លួន (មេ-បា និងព្រះធម្មជាតិ) តួអក្សរ និងតួលេខមួយចំនួន (ដែលជាសញ្ញាផ្គុំគ្នា រវាងព្យញ្ជនៈ និង ស្រះ ដើម្បីបង្កើតជាពាក្យ គឺមិនមែនជាសញ្ញារូបភាពផ្គុំគ្នាទេ) និង បច្ចេកទេសធ្វើស្រែ-ចំការ ការនេសាទ ការងារលោហធាតុ (ដែក ស្ពាន់ ទង់ដែង មាស ប្រាក់...) ។ (តទៅលេខក្រោយ)



**ចាយ សិរីវុឌ្ឍ**

(ឫលក្ខណៈ នៃជនជាតិខ្មែរ)

ពាក្យថា "ខ្មែរមានពូជ" គឺខ្មែរជាអ្នកបានទទួលកេរមរតកដំណែលពី ជីដូន ជីតា និងមានអារ្យធម៌របស់ជនជាតិខ្លួនផ្ទាល់ ។ ក្នុងសម័យបច្ចុប្បន្ននេះ តម្លៃប្រពៃណីរបស់ប្រជាជនខ្មែរ ហាក់ដូចជាមានតែនៅក្នុងទីវត្តអារាមប៉ុណ្ណោះ ។ ដោយហេតុថា ព្រះពុទ្ធសាសនាជាសសរគ្រឹះចម្បងនៃសង្គមជាតិខ្មែរ ជាច្រើនរយឆ្នាំមកហើយ ។ ប៉ុន្តែតម្លៃរបស់ប្រជាជនខ្មែរ មិនមែនមានត្រឹមតែវិស័យសាសនា សីលធម៌ និងសង្គមកិច្ចទេ គឺមាននៅក្នុងវិស័យអក្សរសាស្ត្រ បច្ចេកទេស សេដ្ឋកិច្ច និងសិល្បៈផ្សេងៗ ទៀតដែរ ។

បើយើងសិក្សាតាមដំណើរប្រវត្តិសាស្ត្រ គឺចាប់ផ្តើមពីសតវត្សទី១ នៃគ្រិស្តសករាជ យើងមាន ឯកសារច្រើនបង្គួរ ស្តីពីស្ថានភាពស្រុកខ្មែរ និងជីវភាពនៃប្រជាជនខ្មែរ ។ ក្រោយមកទៀត ឯកសាររបស់ចិន និងឯកសារដែលគេរក្សាទុកនៅ "សាលាបារាំងនៃចុងបូព៌ាប្រទេស" (Ecole Francaise d´Extréme Orient) បានបញ្ជាក់ថា ប្រជាជនខ្មែរ មានការរីកចំរើនជាលំដាប់ ដោយសារមានការខិតខំប្រឹងប្រែងយ៉ាងស្វាហាប់ ដើម្បីឱ្យការចេះដឹងរបស់ខ្លួនកើតឡើងជាបន្តបន្ទាប់ ដែលជាលក្ខណៈពិសេស ថ្លៃថ្លារបស់ជនជាតិខ្មែរតែម្តង ។

**១- ការចេះដឹង ដែលបានមកពីឥណ្ឌា :**

នៅឆ្នាំ ១៩៦០ អ្នកប្រាជ្ញបារាំងឈ្មោះ ហ្សង់ ហ្វីលីយ៉ូស្ហាត៍ Jean Filliozat)[១] បានធ្វើសន្និសីទពីវប្បធម៌ខ្មែរ នៅវិទ្យាស្ថានគរុកោសល្យ នាទីក្រុងភ្នំពេញ ។ លោកបានពន្យល់ថា នៅក្នុងប្រវត្តិសាស្ត្រអារ្យធម៌ឥណ្ឌា បានជ្រាបចូលមកប្រទេសកម្ពុជា ជាលំដាប់ ។ តាមការពិត ខ្មែរមិនបាន "ធ្វើតាម" ឬ "ចម្លងតាម" វប្បធម៌ឥណ្ឌាគ្រប់វិស័យនោះទេ គឺខ្មែរបាន "ចាប់យក" គំនិតស្មារតីឥណ្ឌា ហើយបាន "បង្កើតជារូបរាងថ្មី" ដើម្បីទុកជាសមិទ្ធិកម្មរបស់ខ្លួនផ្ទាល់ ។ ដូច្នេះហើយ ទើបលោក ហ្សង់ ហ្វីលីយ៉ូស្ហាត៍ បានគំណត់សំគាល់ថា អក្សរខ្មែរដំបូងបង្អស់ គ្មានជាប់ទាក់ទងជាមួយនឹងអក្សរឥណ្ឌា ទោះក្នុងរចនាសម្ព័ន្ធក្តី ឬក្នុងការប្រើវាក្យសព្ទសំខាន់ៗក្តី ។ ជាបន្ទាប់មក គឺក្រោយពីវប្បធម៌ឥណ្ឌា បានចូលមកដល់ ទើបគេបានឃើញថា អក្សរខ្មែរ ដែលសរសេរលើសិលាចារឹកជាមុនដំបូងនោះ មានភ្ជាប់ជាមួយនឹងអក្សរនៃភាសាសំស្ក្រឹត (មកពីឥណ្ឌា) ព្រោះអក្សរខ្មែរ ត្រូវបានសរសេរភ្ជាប់នឹង (អក្សរសំស្ក្រឹតជាច្រើន ។

ឥណ្ឌា បានផ្សាយទ្រឹស្តីសាសនា និងអារ្យធម៌របស់គេទៅនៅគ្រប់តំបន់ រហូតដល់ប្រទេស ទីបេត៍ (Tibet) និងប្រទេសខ្មែរ ។ ប៉ុន្តែខ្មែរបានបង្កើតមូលដ្ឋាន

(តទៅលេខក្រោយ)

[១] L´esprit da la civilisation khmére par M. Jean Fillizat, Professeur au Collége de France, Directeur de I´Ecole Francaise Orient, in *Cambodge d´Aujourd´hui*, janvier 1960, Phnom Penh, pp.1-23.



**ភក្ខុ ឌិន ភេន ឥន្ទបញ្ញោ**

សូមគោរពអង្គប្រជុំ
សូមចំរើនពរ លោកស្រី លោកស្រី និងពុទ្ធបរិស័ទទាំងឡាយ ។

ពេលនេះ យើងកំពុងនាំគ្នាធ្វើសិក្ខាសាលាមួយ ប្រធានបទ : **ខ្មែរមានពូជ** ។

ខ្មែរមានពូជ គឺខ្មែរយើងមានពូជល្អៗ មិនចាញ់ជាតិដទៃទេ ។ ខ្មែរយើងមានចំណេះវិជ្ជា មានចរិយាមារយាទ មានប្រពៃណី ទំនៀមទម្លាប់វប្បធម៌ល្អៗ មុនគេឯទៀតទាំងអស់ក្នុងអាស៊ីអាគ្នេយ៍នេះ ។ វាគ្មិន ៣នាក់ សុទ្ធតែថ្នាក់បណ្ឌិត លោកបានលើកយកនូវពូជល្អៗ របស់ខ្មែរយើងជាច្រើន មកជម្រាបជាភស្តុតាងស្រាប់ហើយ ។ អាត្មា អនុមោទនាផង ។ ឥឡូវដល់វេនអាត្មាហើយ នៅចុងក្រោយគេបំផុត អាត្មាអ្នកបួស អ្នកសាសនា អ្នកធម៌អាថ៌ ដូចនេះ សូមជម្រាបផ្នែកសាសនាខ្លះៗ ដូចតទៅនេះ :

**១-ពូជខ្មែរអ្នកប្រាជ្ញ** : ខ្មែរយើងមានអ្នកប្រាជ្ញសូម្បីតែខាងសាសនា ក៏មានអ្នកប្រាជ្ញតាំងពីសម័យនគរភ្នំមក ។ ក្នុងរជ្ជកាលព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន មានព្រះសង្ឃអ្នកប្រាជ្ញខ្មែរពីអង្គ គឺព្រះសង្ឃបាល និងព្រះមន្ទ្រសេន បាននិមន្តទៅជួយប្រែគម្ពីរពុទ្ធសាសនា មានគម្ពីរវិមុត្តិមគ្គជាដើម នៅប្រទេសចិន ។ (ពេលនោះប្រទេសជិតខាងយើង គេមិនទាន់ចូលមកនៅទឹកដីសព្វថ្ងៃនេះទេ លុះពេលគេចូលមក គេនៅអាស្រ័យទឹកដីយើង វប្បធម៌យើង ព្រោះគេមិនសូវមានវប្បធម៌ទេ) ។ សេចក្តីប្រែជាស្នាព្រះហស្តរបស់ព្រះសង្ឃខ្មែរទាំងពីរព្រះអង្គនោះ កាលពីឆ្នាំ ១៩៥៦ សម្តេចសីហនុ យាងទៅប្រទេសចិន គេបានយកមកថ្វាយទត ទុកជានិមិត្តភាពខ្មែរ-ចិនផង ។ ខ្មែរត្រូវតែរក្សាទុកនូវពូជអ្នកប្រាជ្ញ គឺត្រូវខំសិក្សារៀនសូត្រឱ្យចេះដឹង ច្បាប់លាស់ពិតប្រាកដ មានកម្រិតខ្ពស់អាចទៅជាអ្នកប្រាជ្ញអន្តរជាតិបាន ។

**២-ពូជខ្មែរនគរវត្ត :** ព្រះបាទសូរិយាវរ្ម័នទី ២ បានសាងប្រាសាទនគរវត្ត បង្កប់ទុកនូវអត្ថន័យជ្រាលជ្រៅណាស់ ។ នគរមានន័យថា នគរ ឬជាតិ. វត្ត មានន័យថា វត្តឬសាសនា ។ ជាតិ និងសាសនា អាណាចក្រ និងសាសនចក្រ (ពុទ្ធចក្រ) ត្រូវជាមួយគ្នា រួមគ្នាគិតដោះស្រាយកសាង ការពារជាតិ សាសនា មិនមែនដាច់គ្នាស្រលះ គិតតែប្រយោជន៍ផ្នែកខ្លួន មិនគិតប្រយោជន៍ផ្នែកដទៃនោះទេ ប៉ុន្តែត្រូវគិតឱ្យជាតិរស់និងចំរើនរុងរឿងមុន ហើយសឹមជួយសាសនាឱ្យរស់ និងរុងរឿងបន្តបន្ទាប់ជាមួយគ្នាផងដែរ ។ ពូជខ្មែរនគរវត្តនេះ ជ្រៅណាស់ សំខាន់ណាស់ កូនខ្មែរត្រូវតែយល់និងបដិបត្តិឱ្យបាន ។

**៣- ពូជខ្មែរព្រហ្មបាយ័ន :** ព្រះបាទជ័យវរ្ម័នទី ៧ បានសាងប្រាសាទព្រហ្មបាយ័ន ដែលមានសិរសាព្រហ្មជាកំពូល ។ បានសេចក្តីថា ខ្មែរត្រូវតែយកព្រហ្មវិហារធម៌៤ គឺមេត្តា ករុណា មុទិតា ឧបេក្ខា ជាកំពូល ជាមាតា សម្រាប់អនុវត្តន៍ ចាប់ផ្តើមពីអ្នកដឹកនាំគ្រប់ជាន់ថ្នាក់ ត្រូវតែមានព្រហ្មវិហារធម៌ សូម្បីតែប្រជាជន ក៏ត្រូវមានព្រហ្មវិហារធម៌រវាងគ្នា និងគ្នាដែរ ។ (តទៅលេខក្រោយ)

# ជីវិតជាតិខ្មែរក្រោយ ថ្ងៃ៧ មករា ៧៩



**ដោយ : លោក ម៉ម យឹន**

ប្រាំពីរមករា ចិតប្រាំបួន ថ្ងៃនេះទ័ពយួនបានជោគជ័យ
សង្គ្រោះជាតិខ្មែរទាំងប្រុសស្រី បានរស់ផុតភ័យក្តីវេទនា ។
ប៉ុន្តែក្រោយមកជាច្រើនខែ មានជនជាតិខ្មែរតិតឃើញថា
ទ័ពយួនមកនេះប្រាកដជា កំចាត់ខ្មែរណាស្នេហាជាតិ ។
ពិសេសពេលនោះខ្មែរដឹងច្បាស់ ពេលនេះយួនឈ្នះពិតពិឃាដ
បន្តឱ្យស្លាប់ថែមទៅទៀត ដោយប្រើល្បិចស្មៀតបង្អត់បាយ ។
ទ័ពយួនពីរសែនណែនពេញស្រុក រឹបទ្រព្យគ្រប់មុខសែនរីករាយ
នាំទៅស្រុកយួនយ៉ាងសប្បាយ ជាតិខ្មែរកើតស្តាយក្រោកប្រឆាំង ។
ធ្វើឱ្យទ័ពយួនមានកំហឹង ព្រោះខ្មែរទៅពឹងឱ្យមកច្បាំង
ដេញខ្មែរក្រហមដែលជាខ្មាំង ម្តេចខ្មែររារាំងចោទបំពាន ។
ពេលនោះជាតិកើតភ័យខ្លាច ទ័ពយួនសែនកាចបានព្រមាន
ខ្មែរត្រូវនៅស្ងៀមបើចង់បាន ចង់សុខរស់រានមានជីវិត ។
ខ្មែរឃើញដូច្នោះបានសម្រេច នាំគ្នាដើរគ្រាច់រកផ្លូវពិត
ជួយខ្លួនបានរួចពីភ័យភិត នាំគ្នាតាំងចិត្តចេញចោលផ្ទះ ។
ដើរទៅខាងលិចជាជាយដែន ខ្មែរច្រើនរាប់សែនទាំងក្មេងចាស់
ពេលនោះជាពេលសំណាងណាស់ អង្គការយល់ច្បាស់ចេញមកជួយ ។
អង្គការសហប្រជាជាតិ អង្គការល្អស្អាតនាំជំនួយ
ជាស្បៀងអាហារខោអាវភួយ ថ្នាំពេទ្យលើកស្ទួយជនឈឺចាប់ ។
រួចហើយនាំគ្រាច់ចេញទៅ រកញាតិពង្សនៅពីមុនស្រាប់
រស់នៅស្រុកក្រៅជាជាប់លាប់ នាំចេញប្រញាប់ជួបជុំញាតិ ។
ខ្មែរសែនត្រេកអរមានវាសនា ចាកចេញតគ្នាយ៉ាងព្រោងព្រាត
បានសុខចិត្តកាយលែងចង្អៀត ជាមួយក្រុមញាតិឃ្លាតយូរហើយ ។
សង្គមជាតិខ្មែរត្រូវបែកបាក់ ព្រាត់ប្រាសគ្នាជាក់ទុក្ខគ្មានស្បើយ
ទោះបីមករស់សុខក៏ដោយ ចិត្តមិនល្ហែល្ហើយពីទុក្ខភ័យ ។
នឹកឡើងសែនខឹងនឹងពួកព្រៃ ក្រហមពេកក្រៃចិត្តព្រៃផ្សៃ
សម្លាប់ជាតិខ្មែរគ្មានប្រណី រួចហើយដោះដៃថាសង្គ្រោះ ។
ក្រហមដូចគ្នា ចាស់ និងថ្មី គ្រាន់តែក្រឡៃថារំដោះ
តាមពិតកលល្បិចយួនទាំងអស់ មួយសម្លាប់ស្មោះ មួយទៀតជួយ ។
ធ្វើឱ្យមេខ្មែរមានអំណាច ដោយចិត្តអង់អាចយួនលើកស្ទួយ
បានដឹកនាំខ្មែរដោយគ្មានព្រួយ មានតែខ្លួនមួយជួយជាតិពិត ។
ខ្មែរនៅក្រៅស្រុកក្តុកក្តួលណាស់ ព្រោះមើលឃើញច្បាស់នៅក្នុងចិត្ត
ប្រទេសជាតិខ្មែរត្រូវជាប់ស្អិត ក្នុងដៃមេស្និទតែអំណាច ។
នាំជាតិឱ្យធ្លាក់ក្នុងគ្រោះថ្នាក់ មហន្តរាយជាក់ត្រូវភ័យខ្លាច
ជាតិខ្មែរខ្ចាត់ខ្ចាយព្រាចបាចសាច អស់ក្តីអង់អាចត្រឹមនេះហោង ៕

(តមកពីទំព័រទី ០៣)

## សមាគមខ្មែរមានអាយុ...

"We are here today in this wonderful space to celebrate those who have served or is continuing to serve, and to also celebrate those younger generations, as you see will be our bridge to the future. Again we are here to celebrate…to honor the past, and to shape our future together."

CAGP's current President Somrith Pon Som also stated that the reason for the event's existence was "to make sure that we recognize, make sure that we enjoy these thirty years of achievement, and in a way of also bringing people together and resource and educate the general public that after thirty years we're not going away. The situation is still here. I mean the suffering is still here. The lingering of the past is still here. People still suffer mentally and physically. Sometimes, if we don't do this, I think that a lot of people will not hear the information."

The event not only celebrated CAGP's service to the Cambodian-American community since 1979 but to also recognize the Cambodian heritage, voices of community members, and to also celebrate CAGP and their achievements.

(តមកពីទំព័រទី ០៥)

## រៀនសន្សំតក់ៗ...

- អ្នកបច្ចេកទេសខាងអគ្គិសនី បានសន្យាថា អំពូលភ្លើងឈ្មោះ "Nivision" មិនសូវចំណាយកម្លាំងអគ្គិសនីខ្លាំងប៉ុន្មានទេ តែមានតម្លៃខ្ពស់ជាងអំពូលភ្លើងធនធម្មតា ក៏ប៉ុន្តែរបស់នេះ មានគុណភាពល្អ ហើយអាចប្រើបានយូរទៀត ដូចជាអ្នកចាំផ្តើមមូលកុងតាក់បើក អំពូលភ្លើងនេះចាប់ចេញពន្លឺស្រទន់ ពីតូចព្រឹមៗ ឡើងទៅភ្លឺច្បាស់បន្តិចៗម្តងនេះ បង្ហាញឱ្យឃើញថា ចរន្តអគ្គិសនីរត់ទាញតិចៗ។

- អ្នកគួរបន្ថយចំនួនអំពូលភ្លើងខ្លះ នៅតាមបន្ទប់ ដូចជាបន្ទប់ទទួលទានដំណេក ឱ្យពន្លឺត្រឹមតែភ្លឺច្បាស់ល្មមមើលឃើញបាន ។

- អ្នកគួរជៀសវាងបើកទ្វារទូទឹកកកចំហរចោលយូរ ដូចជា អ្នកត្រូវការបើកយកទឹកពិសារ ចាក់ទឹកដាក់កែវរួចបានដើរចេញ ហើយទើបបិទទ្វារទូទៅវិញ ទំលាប់នេះគួរអ្នកជំរុះចោល ពីព្រោះអ្នកបច្ចេកទេសបានរកឃើញថា នៅពេលទ្វារទូទឹកកកចំហរខ្យល់ត្រជាក់ហើរចេញទៅក្រៅ ទំរាំអ្នកបិទទ្វារមកវិញ ខ្យល់ក្តៅពីខាងក្រៅចូលមកជំនួស ដូច្នេះចរន្តអគ្គិសនីត្រូវរត់ទាញជាខ្លាំង ដើម្បីធ្វើខ្យល់ក្តៅនោះឱ្យត្រជាក់ទៅដល់កំរិត ដែលអ្នកបានកំណត់ក្នុងទូទឹកកកនេះវិញ ។

**5. សន្សំប្រាក់ចំណាយលើទឹក :**

នៅទីក្រុងខ្លះ ដែលមានភ្នំច្រើន មិនសូវសម្បូរភ្លៀងធ្លាក់ ដូចជា California អាជ្ញាធរបានចេញប្រកាសឱ្យប្រជាពលរដ្ឋរៀនសន្សំសំចៃទឹក ដោយមានកំណត់ក្នុងការប្រើប្រាស់ ដូចជា មានពេលម៉ោងកំណត់ស្រោចស្មៅ និងដំណាំក្នុងភូមិ ។

នៅទីកន្លែងដទៃទៀត គេកំណត់ឱ្យប្រើទឹកក្នុងបន្ទប់ទឹក ដូចជាមុជ និងប្រើបង្គន់ គឺគេកំណត់ឱ្យមុជស្រោចខ្លួន ហាមមិនឱ្យមុជត្រាំ រីឯបង្គន់អ្នកបង្ហូរទឹកចេញនៅពេលដែលចាំបាច់ប៉ុណ្ណោះ ។ ការសន្សំសំចៃរបៀបនេះ វាពិតជាមានភាពចង្អៀតចង្អល់មែន តែក៏ជាការទំលាប់ដ៏ប្រសើរមួយដែរ ។

ការសន្សំទឹកមិនមានត្រឹមតែស្រោចដំណាំ ឬក៏បន្ទប់ទឹកទេ អ្នកក៏ត្រូវមានស្មារតីប្រុងប្រយ័ត្នទៅលើរបស់ផ្សេងៗទៀត ដូចជា Sink លាងចាន មួលក្បាលទឹកបិទហើយ តែទឹកនៅតែស្រក់តក់ៗ ទៀត គួរអ្នកយកថ្ពិល ឬក៏ធុងណាមួយតូចល្មមមកត្រង់ទឹកទុក អាចប្រើទឹកនោះលាងចាន ឬទុកស្រោចដំណាំក៏បាន ទំរាំដល់ឱកាសអ្នកអាចជួសជុលបាន ។ ម្យ៉ាងទៀត បើអ្នកឮទឹកហូរមិនឈប់នៅបន្ទាប់ពេលអ្នកប្រើបង្គន់ហើយ ពេលនោះអ្នកត្រូវឆាប់ពិនិត្យរកមូលហេតុ ជូនកាលកៅស៊ូនៅខាងក្នុង Toilet Tank បិទមិនជាប់ ឬក៏ត្រូវផ្លាស់ថ្មី ។ នៅពេលអ្នកលាងបន្លែ ឬផ្លែឈើ អ្នកអាចទុកទឹកនោះស្រោចស្មៅ ឬដំណាំបន្តិចបន្តួចក៏បាន អ្នកគួរជៀសវាងបើកទឹកបង្ហូរចោលនៅពេលអ្នកលាងចាន ឬលុបលាងមុខមាត់ ។

មានមតិខ្លះគេយល់ថា មានតែអស់លោកស្ត្រីៗទេ ដែលអាចចេះសន្សំសំចៃដូច្នេះបាន គួរឱ្យខ្មាស់ដែរចំពោះអស់លោកប្រុសៗ តែមិនទាន់ជាយឺតយ៉ាវទេ ៕


**New World Travel II**

**ញូវឺលត្រាវែលធូ**

Specialized in Selling Flight Tickets For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

ខ្មែរប៉ុស្តិ៍
THE KHMER POST
EAST COAST
The Cambodian-American Biweekly News
Email : Khmerpostusa@gmail.com
Call : 267-254-8758

ផ្សព្វផ្សាយលេខទូរស័ព្ទ និងអាសយដ្ឋាន លោកអ្នកក្នុងទំព័រកាសែតខ្មែរប៉ុស្តិ៍ នោះនឹងអាចជួយពាណិជ្ជកម្មលោកអ្នកឱ្យបង្កើននូវអតិថិជនបានយ៉ាងឆាប់រហ័សឡើង ។

មានជំនាញខាងទិញ.លក់ផ្ទះ.ពាណិជ្ជកម្ម. វិនិយោគ ហិរញ្ញវត្ថុ ឬជួល
យើងស្វាគមន៍ចំពោះលោកអ្នកដែលផ្ដើមវិនិយោគ



Vinh Ho, 215-391-9516
Email: vho.realestate@consultant.com
ANCHOR Real Estate Development
320 Oregon Ave, #3B, Philadelphia, PA 19148
Specialize - Buy_Sell_Invest_Finance_Rent ...
Beginner-investors are welcomed!

ឱសថស្ថានខ្មែរ



Sav-Mor PHARMACY
Tel: 215-467-1220
Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447

បំរើលោកអ្នកដោយមិត្តភាព និងទន់ចិត្ត
▶▶Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
▶▶យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ
*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.

NEW PHNOM PENH RESTAURANT
○ មីបំពងគ្រឿងសមុទ្រ ○ គុយទាវគោគ-គុយទាវសាច់គោ
○ ផាត់ថៃ ○ ឡុកឡាក់ ○ មាន់ឆាខ្ញី
○ បាយសាច់ជ្រូកអាំង ○ មីកន្ត្វាំងសាច់គោ ○ បាយឆាសាច់គ្រប់មុខ



TEL.(215) 389-2122
2301 South. 7th Street. Philadelphia, PA 19148
( 7th & Wolf)

NOEL TAX CONSUL TANTS
LICENSED & INSURED
Financial Services
សេវាប្រកបដោយវិជ្ជាជីវៈ :
▸ ខ្ចីប្រាក់ទិញផ្ទះ MORTGAGE
▸ អន្តោប្រវេសន៍ IMMIGRATION
▸ បកប្រែភាសា TRANSLATION
▸ ធ្វើប្រថាប់ត្រាបញ្ជាក់លិខិតផ្លូវការ-NOTARY
▸ មានសេវាមើលកូន នឹងថែទាំផ្ទះសម្បែង
ណូអែល មជ្ឈមណ្ឌលសេវាធ្វើតាក់
សម្រាប់មុខរបរ ឬឯកជន-កត់ត្រាចំណូលចំណាយប្រចាំថ្ងៃនឹងប្រចាំត្រីមាស
អ្នកឯកទេសចំណាន នឹងធ្វើតាក់យ៉ាងប្រសើរជូនលោកអ្នក
អាស័យដ្ឋាន : 6341RISING SUN AVE
Philadelphia . PA 1911
Phone (215) 821-2443
Fax (215) 821-2446
E-mail : noel.tax@gmail.com

DRANOFF ASSOCIATES
*Attorneys at Law*



ដ្រាណុហ្វ អាសូស៊ីយេត (DRANOFF ASSO-CIATE ) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្ដីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះ ដែលមានរបួសរូវាងកាយ ។

ស្ទីវិន ដ្រាណុហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្ដីមានបទពិសោធន៍៣៥ឆ្នាំ ធ្វើជាតំណាងឱ្យឯកជន ដែលពុំមែនឱ្យក្រុមហ៊ុន ឬក្រុមធានារ៉ាប់រងទេ ។

យើងធានាថា ផ្ដល់គុណភាពសេវាច្បាប់យ៉ាងខ្ពស់ ហើយយកចិត្តទុកដាក់ ជាពិសេសដល់អតិថិជនរបស់យើង ។

យើងធ្វើការដោយយកកំរៃពីការងារដែលប្រគល់ឱ្យ - បានន័យថា លោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វី មុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។

ជំនួយខាងផ្លូវច្បាប់អាចផ្ដល់ជូនជាភាសា ស្ប៉ានីស ខ្មែរ វៀតណាម កូរ៉េ និង ចិន ។

សូមអញ្ជើញទូរស័ព្ទមកពេលនេះភ្លាមចុះ ដើម្បីពិគ្រោះសម្ងាត់ដោយមិនគិតថ្លៃ ឬក៏អញ្ជើញមកជួបនៅការិយាល័យយើងក៏បាន ។

DRANOFF ASSOCIATES
121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com

Nationwide
Insurance & Financial Service
សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ
We offer Cheap Price for Every Client
យើងធ្វើជូនគ្រប់គ្រៀងដោយតម្លៃទាប

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញលោកអ្នក |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រងសុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ ធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា
South Philadelphia office:
600 Washington Ave Suite #8 Philadelphia, PA 19147
Tel: (215) 463-1257 , Fax: (215) 463-2036

# ភោជនីយដ្ឋានខ្មែរ

# Kavei
## CAMBODIAN RESTAURANT

Authentic Khmer • Thai • Lao • Vietnamese Phở

**320 W OREGON AVENUE**
**(OREGON MARKET, SOUTH PHILLY)**

**215.952.6688**

**OPEN 7 DAYS A WEEK**
**9am-10pm**









- ភោជនីយដ្ឋានយើងខ្ញុំ ចាប់ផ្តើមបើកពីថ្ងៃហើយ!
- មានម្ហូបខ្មែរពិសេសៗជាច្រើនមុខ ម្ហូបថៃ ឡាវ និង ហ្វៀតណាម
- មានទទួលសម្រាប់ពិធីជប់លាង ខួបកំណើត និង ពិធីផ្សេងៗ
- មានតន្ត្រីសម័យកំដររៀងរាល់ល្ងាច ថ្ងៃសុក្រ-សៅរ៍-អាទិត្យ
- លោកអ្នកអាចទូរស័ព្ទមកកក់តុទុកមុនបាន
- មានកន្លែងចតរថយន្ត ដីធំទូលាយ






**20% OFF**
**DINNER**
(min. order $20)
Cannot Combine with Other Offer
Expire: 12/30/09

**10% OFF**
**DINNER TAKE OUT**
(min. order $15)
Cannot Combine with Other Offer
Expire: 12/30/09

